Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group

# របាយការណ៍ត្រីមាសទី៣

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៣ឆ្នាំ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៥ ៧៩២ ២៩៤ | ៤ ៩៩៩ ៣២៣ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៤ ៧៦៩ ៣០៣ | ៤ ១៩១ ០០៦ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ១ ០២២ ៩៩១ | ៨០៨ ៣១៧ | ៦៦៧ ៩៧០ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី៣ឆ្នាំ២០២០** | **ត្រីមាសទី៣ឆ្នាំ ២០១៩** | **ត្រីមាសទី៣ឆ្នាំ២០១៨** |
| ចំណូលសរុប (លានរៀល) | ១៨១ ៦១៩ | ១៥៥ ៤៤៧ | ១២០ ៨៦០ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៦៥ ៨៤១ | ៤០ ៣៦០ | ២៧ ៩៦៥ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ៥២ ៦២៧ | ៣២ ២៥៤ | ២២ ២៩៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ៥៤ ៥០៣ | ៣៤ ៦៥២ | ២៤ ៨២៦ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី៣ឆ្នាំ២០២០** | **២០១៩** | **២០១៨** |
| អនុបាតសាធនភាព (ភាគរយ) | ១៨,៦ | ១៩,៤ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤៦៦ | ៥១៨ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ២៩៩,៧ | ១១៣,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ១,១២ | ០,៣០ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៩,៥ | ៥៧,០ | ៦៣,៤ |
| | **ត្រីមាសទី៣ឆ្នាំ២០២០** | **ត្រីមាសទី៣ឆ្នាំ ២០១៩** | **ត្រីមាសទី៣ឆ្នាំ២០១៨** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ០,៩១ | ០,៦១ | ០,៤៦ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ៥,១៤ | ៣,៤៦ | ៣,៣៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៩០ | ១៥៧ | ១៤៩ |

[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# គ្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



អ្នកស្រី Voranuch DEJAKAISAYA
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជាបឋម ខ្ញុំសូមចែករំលែកព័ត៌មានដ៏វិសេសវិសាលរបស់យើង ដែលធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាបណ្ណធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០២០ ហើយបន្ទាប់មក យើងបានផ្លាស់ប្តូរឈ្មោះពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត ទៅជា **ធនាគារ ហត្ថា ម.ក** កាលពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០២០ ដែលករណីនេះ ជាសមិទ្ធផលគួរឲ្យកត់សម្គាល់ កើតឡើងពីលទ្ធផលនៃការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីពង្រឹងក្រុមហ៊ុន និងបំពេញតាមតម្រូវការបទប្បញ្ញត្តិ ក៏ដូចជាការរំពឹងទុករបស់អតិថិជន។ ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់និយ័តករ អតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត ដែលបានគាំទ្រ និងទុកចិត្តមកលើអាជីវកម្មរបស់យើងខ្ញុំ។ **ធនាគារ ហត្ថា ម.ក** នឹងឆក់យកឱកាសនេះដើម្បីផ្តល់ជូននូវផលិតផល និងសេវាកម្មកាន់តែទូលំទូលាយដល់ទីផ្សារអាជីវកម្មទាំងនៅក្នុងស្រុក និងអន្តរជាតិ សម្រាប់ឆ្នាំខាងមុខទៀត។

ជំងឺកូវីដ១៩ នៅតែជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចទាំងអស់នៅទូទាំងពិភពលោក ហើយស្ថានភាពនៅប្រទេសកម្ពុជាមានសភាពល្អប្រសើរ បើប្រៀបធៀបនឹងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ាន។ ទោះបីជា យើងមិនអាចគេចផុតពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក៏ដោយ ក៏យើងសង្ឃឹមថាវានៅតែបន្តងើបឡើងវិញបាន។

ជាអាទិភាព យើងចាំបាច់ត្រូវតែជួយដល់អតិថិជនរបស់យើង ជាក់ស្តែងនៅចុងខែកញ្ញា ឆ្នាំ២០២០ ធនាគារ ហត្ថា ម.ក បានអនុវត្តកម្មវិធីការរៀបចំឥណទានសារឡើងវិញ ជូនដល់អតិថិជនជាង ១២.០០០ នាក់ ដែលរងផលប៉ះពាល់ដោយស្ថានភាពជំងឺកូវីដ១៩ ជាពិសេសអតិថិជនដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងវិស័យវាយនភ័ណ្ឌ។

ទន្ទឹមនឹងនេះ វិស័យធុរកិច្ចមួយចំនួន បានដំណើរការសកម្មភាពរបស់ខ្លួនឡើងវិញយ៉ាងល្អ ដូចជាលទ្ធផលអាជីវកម្មរបស់យើង បានទទួលលទ្ធផលគួរជាទីពេញចិត្តនៅក្នុងត្រីមាសនេះ។ យើងបានបង្កើនផលប័ត្រឥណទានរហូតដល់ ១ ១២៨ លានដុល្លារអាមេរិក កើនឡើង ៥,៥% ភាគរយ លើសត្រីមាសមុន។ ប្រាក់បញ្ញើសន្សំរបស់យើងបានបង្កើនដល់ ៦៨៦ លានដុល្លារអាមេរិក កើនឡើង ១៧% ភាគរយ បើធៀបពីមួយត្រីមាស ទៅមួយត្រីមាស ដែលឆ្លុះបញ្ចាំងពីការទុកចិត្តរបស់អតិថិជនមកលើស្ថានភាពធនាគារពាណិជ្ជកម្ម ក៏ដូចជាការកែលម្អទស្សនវិស័យអាជីវកម្មរបស់ខ្លួន។ ឥណទានមិនដំណើរការរបស់យើងក៏បានកែលម្អពី ២,៥៦% ទៅ ១,៤៤% ផងដែរ ដោយសារយើងបានបន្តពង្រឹងការគ្រប់គ្រងគុណភាពទ្រព្យសម្បត្តិបានច្បាស់លាស់ ដែលទាំងអស់នេះ វាជានិន្នាការវិជ្ជមាន ក្នុងការជួយឱ្យទទួលបានលទ្ធផលរឹងមាំជាងមុន បើប្រៀបធៀបទៅនឹងត្រីមាសទី២នេះ។ ក្នុងអំឡុងពេលនេះ យើងក៏បានណែនាំកម្មវិធីសេវាកម្មធនាគារចល័តថ្មី ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន និងលើកកម្ពស់អាទិភាពរបស់យើងនៅក្នុងអាជីវកម្មឌីជីថលតទៅមុខ។

ទោះបីជំងឺរាតត្បាតជាសកល នៅតែបន្តអូសបន្លាយពេល ដែលមានភាពមិនទាន់ច្បាស់លាស់ និងគួរឱ្យព្រួយបារម្ភ យើងសូមធានាឱ្យមានការប្រុងប្រយ័ត្នក្នុងការធ្វើប្រតិបត្តិការធនាគារ ចំពោះការរីកចម្រើនជាមួយនឹងទិសដៅប្រកបដោយសុវត្ថិភាព សមហេតុផល និងផ្តល់ការគាំទ្រដល់អតិថិជនដែលរងផលប៉ះពាល់តាមដែលអាចធ្វើទៅបាន។ ការកែទម្រង់ផ្ទៃក្នុង របស់យើង ដើម្បីឆ្ពោះទៅរកសមត្ថភាពជាធនាគារពាណិជ្ជដ៏ធំ និងខាងឌីជីថល ដោយធានាថាយើងបានត្រៀមខ្លួនរួចជាស្រេចសម្រាប់បម្រើអតិថិជន និងជួយអតិថិជនឱ្យទទួលបានជោគជ័យនៅក្នុងគ្រាដ៏លំបាកនេះ។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២០
ហត្ថលេខា និង ត្រា

លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល

## សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

ការតស៊ូបំពេញការងារផ្តល់ដើមទុនជួយដល់ប្រជាពលរដ្ឋកម្ពុជា និងអភិវឌ្ឍក្រុមហ៊ុនអស់រយៈពេលជាង ២៦ឆ្នាំ កន្លងមកនេះ ទោះបីស្ថិតក្នុងស្ថានភាពសង្គ្រាមតាមព្រំដែន វិបត្តិសេដ្ឋកិច្ច គ្រោះទឹកជំនន់ និងការរីករាលដាលជំងឺ COVID-19 លើសកលលោក យ៉ាងណាក៏ដោយ យើងបានពួតដៃគ្នាធ្វើដំណើរប្រកបដោយភាពជឿជាក់ ស្មោះត្រង់ ពុះពារ និងខិតខំប្រឹងប្រែងបំផុតដើម្បីកសាង និងពង្រីកស្ថាប័នរបស់យើងឲ្យរីកចម្រើនទៅមុខ ជាមួយនឹងយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ ការជឿទុកចិត្តពីសំណាក់អតិថិជន និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ទើបឥឡូវនេះ យើងក៏សម្រេចបាននូវសមិទ្ធផលជាទីមោទនា និងដ៏ល្អអស្ចារ្យដោយបានកម្លាយខ្លួនជាធនាគារពាណិជ្ជយ៉ាងពេញលេញ ដែលមានឈ្មោះជាផ្លូវការថា **ធនាគារ ហត្ថា ម.ក**។ ការកម្លាយខ្លួនរបស់ធនាគារ ហត្ថា ម.ក គឺជាមោទនភាពមួយរបស់យើងទាំងអស់គ្នាដែលបានរួមចំណែកយ៉ាងសស្រាក់សស្រាំក្នុងការនាំយកមុខមាត់ថ្មីជាប្រវត្តិសាស្ត្រដ៏ល្អប្រពៃមកឲ្យស្ថាប័នយើង ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បុគ្គលិកទាំងអស់បានត្រៀមខ្លួនរួចជាស្រេចក្នុងការបម្រើសេវាកម្មធនាគារជូនអតិថិជន តាមបែបបច្ចេកវិទ្យាទំនើប និងមានភាពសាមញ្ញ ដើម្បីធ្វើឲ្យធនាគារ ហត្ថា ម.ក ក្លាយជាធនាគារនាំមុខគេនៅក្នុងពេលអនាគត។

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ធនាគារ ហត្ថា ម.ក បានទទួលលទ្ធផលល្អប្រសើរដូចខាងក្រោម៖

-សមតុល្យប្រាក់កម្ចីក្រោមផែនការតែចំនួន ៥.៦ លានដុល្លារអាមេរិក<br>
-ប្រាក់បញ្ញើសន្សំលើសផែនការប្រមាណជិត ១៣ លានដុល្លារអាមេរិក<br>
-ប្រាក់ចំណេញលើសផែនការប្រមាណជិត ៣,៦ លានដុល្លារអាមេរិក<br>
-ឥណទានមិនដំណើរការគឺ ១,៤៤% ខ្ពស់ជាងផែនការចំនួន ០,៧៤%

ជាចុងក្រោយ សូមគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់បន្តខិតខំប្រឹងប្រែងធ្វើការងារតាមជំនាញរៀងៗខ្លួន និងពង្រីកពង្រឹងចំណេះជំនាញធនាគារបន្ថែម ដើម្បីបន្តដំណើរការរបស់យើងទៅមុខទៀត ដូចពាក្យស្លោករបស់យើង «រួមគ្នាសាងអនាគតដ៏ប្រសើរ» ។ យើងទាំងអស់គ្នា នឹងបន្តពួតដៃគ្នាកសាងកេរ្តិ៍ឈ្មោះ **ធនាគារ ហត្ថា ម.ក** ឲ្យកាន់តែល្បីរន្ទឺទាំងក្នុងប្រទេសកម្ពុជា និងលើឆាកអន្តរជាតិ៕

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២០<br>
ហត្ថលេខា



លោកឧកញ៉ា ហួត អៀងតុង<br>
ប្រធានអគ្គនាយក

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii
សមាសភាពក្រុមប្រឹក្សាភិបាល ........ iii
សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iv
សេចក្ដីថ្លែងរបស់ប្រធានអគ្គនាយក ........ v
ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១
ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១
ខ- លក្ខណៈនៃធុរកិច្ច ........ ១
គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២
ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២
ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២
ខ- រចនាសម្ព័ន្ធចំណូល ........ ៣
ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៤
ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៥
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៥
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៥
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៥
ឃ-ផលប៉ះពាល់នៃការប្ដូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៥
ង- ផលប៉ះពាល់នៃអតិផរណា ........ ៦
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៦

## ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារ ហត្ថា ម.ក |
| ឈ្មោះជាអក្សរឡាតាំង | Hattha Bank Plc. |
| កូដស្តង់ដារ | KH20000718B4 |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hatthabank.com |
| អ៊ីម៉ែល | info@hatthabank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ-៥៦ ចេញដោយៈ ធនាគារជាតិនៃកម្ពុជាកាលបរិច្ឆេទៈ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទៈ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងធនាគារ ហត្ថា ម.ក ដោយ | លោកឧកញ៉ា ហួត អៀងតុង |

ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ ហត្ថា ម.ក គឺជាធនាគារមួយក្នុងចំណោមធនាគារឈានមុខផ្សេងទៀតនៅកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០។ ជាមួយបទពិសោធន៍ក្នុងការបម្រើសេវាហិរញ្ញវត្ថុទៅកាន់ប្រជាជនកម្ពុជាអស់រយៈពេលជាង ២៦ឆ្នាំ ក្រោយការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ខ្លួន ធនាគារ ហត្ថា បានកែលម្អ និងដាក់ឲ្យប្រើប្រាស់បន្ថែមនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផ្សេងទៀតក្នុងនោះមានដូចជា៖ ការធ្វើឲ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័ត (Hattha Mobile) ដាក់ឲ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ឆ្លងធនាគារ សេវាឥណទានវិបារូបន៍ សេវាបញ្ញើសន្សំផលច្រើន (HYSA Flexi and HYSA Corporate) និងការត្រៀមខ្លួនក្នុងការផ្តល់ជូនសេវាធនាគារថ្មីៗផ្សេងទៀត បន្ថែមលើសេវាដែលមានស្រាប់ដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ។

គិតត្រឹម ខែ កញ្ញា ឆ្នាំ ២០២០ សមតុល្យប្រាក់បញ្ញើសន្សំ របស់ ធនាគារ ហត្ថា មានចំនួនជាង ៦៧៦ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនប្រាក់បញ្ញើសន្សំ ២៦០ ៧៥៩ នាក់ និងផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ៨៤៤ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១២៨ ៧៦០នាក់ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំង នៅទូទាំងប្រទេស។

ធនាគារ ហត្ថា គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ ក្រុងស្រ៊ី។ ធនាគារ ក្រុងស្រ៊ី (ធនាគារ អាយុធ្យា ម.ក និង ក្រុមហ៊ុនជាបុត្រសម្ព័ន្ធ) គឺជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅក្នុងព្រះរាជាណាចក្រថៃ ដោយយោងលើទំហំទ្រព្យសកម្ម ផលប័ត្រឥណទាន និងប្រាក់បញ្ញើសន្សំ និងជាធនាគារមួយក្នុងចំណោមធនាគារ D-SIBs ចំនួនប្រាំ ដែលបានធ្វើប្រតិបត្តិការអាជីវកម្មជូនអតិថិជនរបស់ខ្លួនអស់រយៈពេល ៧៥ ឆ្នាំ មកហើយនៅក្នុងព្រះរាជាណាចក្រថៃ។ ធនាគារ ក្រុងស្រ៊ី គឺជាសមាជិកយុទ្ធសាស្ត្ររបស់សម្ព័ន្ធហិរញ្ញវត្ថុ MUFG ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបង្អស់នៅជប៉ុន ក៏ដូចជាសម្ព័ន្ធហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំៗផ្សេងទៀតនៅលើពិភពលោក។

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ដូចដែលបានដឹងរួចមកហើយ ការរីករាតត្បាតនៃជម្ងឺកូវីដ១៩ បានបង្កឲ្យមានផលលំបាកយ៉ាងខ្លាំងដល់សកម្មភាពអាជីវកម្មសំខាន់ៗជាច្រើនទាំងនៅក្នុងប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូល។ ទោះជាយ៉ាងនេះក្តី ធនាគារ ហត្ថា នៅតែបន្តប្រតិបត្តិការរបស់ខ្លួនយ៉ាងរឹងមាំ និងប្រកបដោយទំនុកចិត្តពីអតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធ។ ស្របតាមគោលដៅអាជីវកម្មយូរអង្វែងរបស់ខ្លួន នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០២០ កំណត់សម្គាល់សំខាន់ថ្មីមួយទៀតបានលេចរូបរាងឡើង នោះគឺ ការកម្លាយខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំ (ហត្ថាកសិករ លីមីតធីត) មកជាធនាគារពាណិជ្ជ (ធនាគារ ហត្ថា ម.ក) ដើម្បីធានាបាននូវការផ្តល់ជូនសេវាហិរញ្ញវត្ថុកាន់តែសម្បូរបែប និងទូលំទូលាយទៅកាន់អតិថិជន។

ស្របតាមស្មារតីរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងផ្តល់ឥណទានដែលមានការប្រាក់ទាបដើម្បីជំរុញដល់វឌ្ឍនភាពរបស់សហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា ធនាគារ ហត្ថា ផ្តល់ជូននូវអត្រាការប្រាក់យ៉ាងពិសេសត្រឹមតែ ៧% ក្នុងមួយឆ្នាំ ដើម្បីទ្រទ្រង់ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដែលជាផ្នែកមួយនៃការចូលរួមក្នុងគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME Co-Financing Scheme) ក៏ដូចជាដើម្បីបង្កើនសន្ទុះនៃការរីកចម្រើនដល់សេដ្ឋកិច្ចជាតិ។ ទាំងនេះគឺជាសក្ខីភាពយ៉ាងប្រត្យក្សដែលថា ធនាគារ ហត្ថា គឺជាធនាគារមួយមានសមត្ថភាពពេញលេញ និងចក្ខុវិស័យច្បាស់លាស់ក្នុងការរក្សាបាននូវស្ថិរភាពអាជីវកម្មនៅលើទីផ្សារ ក៏ដូចជារួមចំណែកក្នុងការផ្តល់ជូនភាពរីកចម្រើនទៅកាន់អតិថិជន និងសង្គមជាតិរបស់ខ្លួន។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៧៣ ៨៣៣ | ១៧៥ ៥១៩ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ១៣៤ ៩៧៨ | ១ ១៣៧ ៥៤៨ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |

| | | |
|---|---|---|
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៦៣ ៩៣៣ | ២៦០ ៧៥៧ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៥៩៧ ១៨៧ | ៦៧៦ ៩៩៣ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥២ ៩៨១ | ៥០ ៨០៤ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៨ ៩៧៨ | ៩ ០៣១ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ១៦០ ៤៦៦ | ២០១ ២១០ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ២ ៥៤៥ ០៦៤ | ៤ ២៧២ ៤៥៧ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៤២ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ៤០៩ | ៥ ០៥២ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ ២០២០ | | ត្រីមាសទី៣ ឆ្នាំ ២០១៩ | | ត្រីមាសទី៣ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៧៤ ៩៧៦ | ៩៦,៣ | ១៤៩ ៤០៦ | ៩៦,១ | ១១៥ ៥៩៣ | ៩៥,៦ |
| ២ | ចំណូលផ្សេងៗ | ៦ ៦៤៣ | ៣,៧ | ៦ ០៤១ | ៣,៩ | ៥ ២៦៧ | ៤,៤ |
| ចំណូលសរុប | | ១៨១ ៦១៩ | | ១៥៥ ៤៤៧ | | ១២០ ៨៦០ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ធនាគារហត្ថាត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ធនាគារ ហត្ថា តែប៉ុណ្ណោះ ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**ការវិភាគចំណូល**

ធនាគារ ហត្ថា មានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ធនាគារ ហត្ថា ដែលមានរហូតដល់ ៩៦,៣% នៃចំណូលសរុប។

### ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា យល់ថា ផលប៉ះពាល់ជាអវិជ្ជនៃការរីករាលដាលកូវីដ១៩ បានចាប់ផ្តើមមានធូរស្បើយបន្តិចនៅក្នុងត្រីមាសនេះ ជាលទ្ធផលធ្វើឱ្យប្រាក់ចំណេញមានការកើនឡើងលើសពីត្រីមាសមុន។

### គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា យល់ថាការលក់ និងចំណូលមានការកើនឡើងនៅក្នុងដំណាក់កាលកូវីដ១៩នេះ។

### ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារ ហត្ថា បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង- ផលប៉ះពាល់នៃអតិផរណា**

ធនាគារ ហត្ថា មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល**

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២០ នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការសំខាន់ៗជាច្រើនដើម្បីធានាឱ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ចជាតិ ដូចជាការបន្តផ្តល់ហិរញ្ញប្បទានគាំទ្រនិយោជិតដែលត្រូវបានព្យួរការងារ (ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ស្បែកជើង និងទេសចរណ៍) និងគ្រួសារដែលមានប័ណ្ណក្រីក្រ ព្រមទាំងបន្តអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុផ្សេងៗទៀត។

បន្ថែមពីលើនេះ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានជម្រាបជូនដំណឹងអំពីការកែសម្រួលលក្ខខណ្ឌធ្វើដំណើររបស់ជនបរទេស មកកាន់ប្រទេសកម្ពុជា ដែលនឹងអនុវត្តយន្តការធានា ដើម្បីជួយសម្រួលអ្នកដំណើរបរទេសដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមានការធានា ឬមានការអញ្ជើញតែមិនមានការធានា ឬ មិនមានការអញ្ជើញ និងមិនមានការធានា ឬ អ្នកធ្វើដំណើរបរទេសទូទៅ។ ការកែសម្រួលនេះ ធ្វើឡើងក្នុងវត្ថុបំណងផ្តល់ភាពងាយស្រួលដល់អ្នកធ្វើដំណើរបរទេសដែលបានមកដល់ ឬគ្រោងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដោយឈរលើលក្ខខណ្ឌសំខាន់ដូចជា៖

- មុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជា៖ អ្នកធ្វើដំណើរបរទេស ត្រូវមានឯកសារជាក់លាក់មួយចំនួនរួមមាន វិញ្ញាបនបត្របញ្ជាក់សុខភាព លិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ និងទិដ្ឋាការដែលមានសុពលភាព ស្របតាមនីតិវិធី និងលិខិត ឬ ឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ។
- ពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជា៖ អ្នកធ្វើដំណើរបរទេសត្រូវបង្ហាញទិដ្ឋាការដែលមានសុពលភាព និងបន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវខាងលើ អ្នកដំណើរបរទេសនឹងមានសិទ្ធិប្រើប្រាស់ផ្លូវអាទិភាពពិសេស ដើម្បីទទួលបានការពិនិត្យសុខភាព និងការយកសំណាក ទាក់ទងនឹងជំងឺ កូវីដ ១៩។

**ហត្ថលេខារបស់អភិបាល ធនាគារ ហត្ថា ម.ក**

កាលបរិច្ឆេទ៖ ១៣ ខែ វិច្ឆិកា ឆ្នាំ២០២០
បានអាន និងឯកភាព

លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ១៣ ខែ វិច្ឆិកា ឆ្នាំ២០២០
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group